# ការសំភាសន៍របស់អ្នកមីង សាវេត

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ សាវេត

## <u>ការសង្ខេបប្រវត្តិរបស់អ្នកមីង សាវេត</u>

អ្នកមីង សាវេត មានអាយុ50 ឆ្នាំ នៅក្នុងឆ្នាំ 2018 អ្នកមីង សាវេត មានភេទស្រី អ្នកមីង សាវេត មានទីលំនៅបច្ចុប្បន្ន នៅភូមិទី5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថា BYU ហើយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយ នឹងប្រវត្តិរបស់ជួនតាចឹងហាសមីង ចឹងនៅពេលដែរខ្ញុំបានសំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង ចឹងមីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ ចាំ! មានអីដាក់ទៅ

កៈ បាទ! ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍មីងខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មីងគឺនៅកថ្ងៃទី9 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានធ្វើឡើងនៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចឹងសំរាប់មីងឈ្មោះពេញរបស់មីងនឹង មានឈ្មោះអីគេដែរទើងមីង?

ខៈ ខ្ញុំឈ្មោះ សាវេត

កៈ មីងឈ្មោះ សាវេត ចុះមានឈ្មោះហៅក្រៅទេមីង?

ខៈ អត់មានទេ មានតែឈ្មោះមួយនឹងគ្មានឈ្មោះអីផ្សេងទេ

កៈ ចុះតាំងពីក្មេងមានធ្លាប់មាននរណាហៅឈ្មោះមីងអីផ្សេងទេ?

ខ៖  អត់មានទេ មានតែឈ្មោះមួយនឹង

ក៖  ចុះមីងសព្វថ្ងៃនឹង តើមីងមានអាយុប៉ុន្មានដែរសព្វថ្ងៃនឹង?

ខ៖  ខ្ញុំអាយុ50ឆ្នាំ

ក៖  មីងមានអាយុ50ឆ្នាំ ចុះមីងកើតនៅថ្ងៃខែឆ្នាំណាមីងមានចងចាំទេ?

ខ៖  ខ្ញុំអត់ចងចាំទេ

ក៖  ចុះឆ្នាំក៏មីងមិនចាំដែរ?

ខ៖  បើឆ្នាំវិញខ្ញុំចាំ

ក៖  មីងកើតនៅឆ្នាំប៉ុន្មានដែរមីង?

ខ៖  បើឆ្នាំណុងខ្ញុំមិនចងចាំទេ ខ្ញុំចាំតែឆ្នាំរាល់ថ្ងៃនឹង

ក៖  ចឹងឆ្នាំអីគេដែរមីង?

ខ៖  ខ្ញុំឆ្នាំរកា

ក៖  មីងឆ្នាំរកាណមីង ចឹងមីងកើតនៅឆ្នាំ 1968មីង?

ខ៖  ចឹងហោសក្មួយ

ក៖  បាទមីង ចុះមីងកើតនៅណាដែរមីងមានចងចាំទេមីង?

ខ៖  ខ្ញុំកើតនៅកំពង់ចាម

ក៖  ចុះនៅភូមិឃុំអីគេដែរមីង?

ខ៖  កើតនៅឃុំស្នួង

ក៖  ចុះភូមិវិញមីង?

ខ៖  នៅភូមិរកាខ្នុច

ក៖  នៅភូមិរកាខ្នុច ឃុំស្នួង ?

ខ៖  នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

ក៖  នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម
ប៉ុន្តែស្រុកត្បូងឃ្មុំឥឡូវនឹងឡើងជាខេត្តហើយមែនទេមីង?

ខ៖ ចា៎!ឥឡូវនឹងវាឡើងជាខេត្តហើយនឹង

ក៖ អូ៎!បាទ ចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួន6នាក់

ក៖ មីងមានបងប្អូនចំនួន6នាក់ ចុះមីងជាកូនទីប៉ុន្មានដែរដែរទៅ?

ខ៖ ខ្ញុំជាកូនបងគេ

ក៖ ចុះមីងមានស្រីប៉ុន្មាននាក់ ហើយមានប្រុសប៉ុន្មាននាក់ដែរមីង?

ខ៖ មានស្រី3នាក់ នឹងប្រុស3នាក់

ក៖ មានស្រី3នាក់ នឹងប្រុស3នាក់
ចុះមីងអាចប្រាប់ឈ្មោះបងប្អូនរបស់មីងមកខ្ញុំបានទេមីង
ថាគាត់មានឈ្មោះអីគេខ្លះដែរចឹងហាស?

ខ៖ ពូកគាត់បានស្លាប់បាត់អស់ហើយនឹង

ក៖ ចឹងនៅសល់តែមីងមួយទេចឹង?

ខ៖ នៅសល់ប្អូនប្រុស2នាក់ដែរ

ក៖ អូ៎!នៅសល់តែ2នាក់ ចុះពូកគាត់មានឈ្មោះអីគេដែរចឹងហាសមីង?

ខ៖ ឈ្មោះប្អូនថា នឹងប្អូនធា

ក៖ ចុះមីងមានចងចាំកាលពីមីងនៅក្មេងអាយុប្រហែលជា6ឆ្នាំទៅ7ឆ្នាំ រឺមួយក៏អាយុ10ឆ្នាំ មីងមានធ្លាប់បានធ្វើអីគេខ្លះដែរជាមួយពូកគាត់ហាស ដូចជាលក្ខណះថា........?

ខ៖ មានធ្វើអី មានតែធ្វើស្រែចំការនឹង

ក៖ ចុះលក្ខណះថាលេងឡឹកបាយឡ លេងចុយលេងអី តើមីងធ្លាប់លេងទេ?

ខ៖ ខ្ញុំមិនដែរបានលេងជាមួយបងប្អូនទេ ខ្ញុំធ្លាប់តែលេងជាមួយគេអ្នកដទៃនឹង

ក៖ លក្ខណះលេងអីគេដែរទៅមីង?

ខ៖ លេងដួសដីដាក់ត្រឡោកចឹងហាស ចុះនៅស្រុកស្រែមានស្អី លេងបាយខំអីនឹងហាស

ក៖ បាទមីងចុះដូចជាបងប្អូនរបស់មីងដូចជាគាត់ធ្វើអីគេដែរមីង?

ខ៖ ទៅនៅស្រែ ហើយធ្វើស្រែ

កៈ ប៉ុន្តែនៅណាដែរមីង?

ខៈ នៅស្វងនឹង

កៈ នៅស្វងណុងហោសមីង?

ខៈ ចា៎!គេធ្វើតែស្រែចំការនឹង

កៈ អូ៎បាទមីង! ចុះម្ដាយរបស់មីងមានឈ្មោះអីគេដែរមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់មានឈ្មោះយាយមូន

កៈ ចុះឪពុកវិញមីង?

ខៈ ឪពុកឈ្មោះ តាដុយ គាត់ស្លាប់អស់ហើយនឹង

កៈ ចុះគាត់អាយុប៉ុន្មានដែរមីងមានចងចាំទេ?

ខៈ ឪពុកម្ដាយរបស់ខ្ញុំនឹង កាលគាត់ស្លាប់នឹងម្ដាយរបស់ខ្ញុំគាត់អាយុ62ឆ្នាំ ហើយឪពុករបស់ខ្ញុំគាត់អាយុ76ឆ្នាំ ប៉ុន្តែពួកគាត់ស្លាប់ជាង10ឆ្នាំហើយនឹង ខ្ញុំមិនសូវច្បាស់ដែរនឹង

កៈ ចុះពួកគាត់កើតនៅណាដែរមីង?

ខៈ កើតនៅណុងដែរស្រុកកំណើតពួកគាត់នៅណុងឯង

កៈ ពួកគាត់កើតនៅស្វងទាំងអស់គ្នាហោសមីង?

ខៈ ចា៎! នៅស្វងទាំងអស់គ្នានឹង

កៈ អូ៎!បាទ ចុះឪពុករបស់មីងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ នេះគាត់ធ្វើស្រែ នឹងធ្វើចំការជាអ្នកកសិករនឹង

កៈ ចុះគាត់ជាមនុស្សបែបណាដែរមីង គាត់កាចរឺមួយក៏ស្លូតដែរមីង?

ខៈ គាត់ជាមនុស្សធម្មតា គាត់ស្លូតនឹង

កៈ ចុះម្ដាយរបស់មីងវិញ?

ខៈ កាត់ស្លូតនឹងគាត់នៅតែផ្ទះទេ

កៈ ប៉ុន្តែគាតើធ្វើអីគេដែរមីង?

ខ៖ គាត់អត់មានធ្វើអីទេ គាត់ធ្វើតែស្រែនឹង នៅតែផ្ទះដាំបាយអោយកូនស៊ីទៅ
យើងទៅធ្វើការចឹងទៅ

ក៖ ចុះមីងមានចងចាំថាកាលពីមីងនៅជាមួយម្ដាយឪពុករបស់មីង
តើមីងធ្លាប់បានធ្វើអីគេខ្លះជាមួយគាត់ដែរទេ?

ខ៖ មានធ្វើអី មានតែធ្វើធម្មតាដូចតែយើងរាល់ថ្ងៃនឹងហាស

ក៖ ដូចថាមីងធ្លាប់ទៅស្រែជាមួយគ្នា?

ខ៖ ចាំ!ទៅស្ទូងស្រែ ហើយហូបបាយ នឹងហូបទឹកអីជាមួយគ្នាចឹងហាស

ក៖ អូ៎!បាទមីង
ចុះឪពុកម្ដាយរបស់មីងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់ពួកគាត់កាលពីពួកគាត់នៅក្មេងទៅ
មីងដែរទេ?

ខ៖ គាត់មិនដែរនិយាយផង ហើយខ្ញុំក៏មិនដែរសួរទេ

ក៖
អូ៎!ចឹងគាត់មិនដែរបានប្រាប់ថាកាលពីនៅតូចៗនឹងពួកគាត់ធ្លាប់បានធ្វើអីគេទេណាមីង?

ខ៖ ចាំ!មិនដែរបាននិយាយអីទេ ហើយខ្ញុំក៏មិនដែរបានសួរគាត់ដែរ

ក៖ ចុះយាយតាខាងឪពុកមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ គាត់វាយូរឆ្នាំហើយខ្ញុំចង់ភ្លេចអស់ហើយនឹង ខ្ញុំចាំប៉ុន្តែវាយូរ
យាយតារបស់ខ្ញុំនឹងសុទ្ធតែជាអាចារ្យវត្តហោស ខ្ញុំនឹងវាមិនដឹងថាវាយ៉ាងម៉េចដែរ
ពីព្រោះខ្ញុំបានបែកពីគាត់វាច្រើនឆ្នាំដែរនឹង

ក៖ ចឹងមានន័យថាវាយូរដែរហើយណាមីង?

ខ៖ យូរហើយ ហើយគាត់ស្លាប់តាំងពីខ្ញុំនៅតូចៗចឹងហាស ហើយចាំវាមិនបាន
មិនដឹងថាចាំវារបៀបម៉េចទេ

ក៖ ចឹងយាយតាខាងឪពុក
នឹងយាយតាខាងម្ដាយនឹងមីងអត់មានចងចាំពួកគាត់ទាំងអស់គ្នានឹងហោសមីង?

ខ៖ ខ្ញុំមិនទាន់ទេម្ដាយខាងម្ដាយរបស់ខ្ញុំនឹង

ក៖ ប៉ុន្តែខាងឪពុកមីងចងចាំ?

ខ៖  ខ្ញុំចាំបានខ្លះដែរ

ក៖  ចឹងមីងចាំឈ្មោះគាត់នឹង មានឈ្មោះអីគេដែរមីង?

ខ៖  ឈ្មោះយាយយែម

ក៖  ឈ្មោះយាយយែម នឹងតាវិញ?

ខ៖  តាឈ្មោះ តាដុច

ក៖  មានឈ្មោះតាដុចហោសមីង?

ខ៖  ចាំ! ខ្ញុំចាំបានតែប៉ុណ្ណឹង

ក៖  ចុះមីងមាមចងចាំថាគាត់កើតនៅណាមីងមានដឹងទេ?

ខ៖  ខ្ញុំមិនដឹងដែរនឹងខ្ញុំមិនដឹងទេ

ក៖  មីងមនបានដឹងទេ?

ខ៖  ពីព្រោះខ្ញុំកើតនៅស្រុកនឹងចឹងខ្ញុំអត់បានសួរដែរ

ក៖  ចុះមីងមកនៅទីក្រុងភ្នំពេញនឹងជាគ្រួសារនឹយូរនៅមីង?

ខ៖  យូរដែរហើយនឹង ជាង20ឆ្នាំហើយនឹង

ក៖  អូ្!មកនៅជាង20ឆ្នាំហើយហោសមីង?

ខ៖  ខ្ញុំមកនៅតាំងពីមិនទាន់មានកូន ឥឡូវនឹងខ្ញុំមានដល់ទៅចៅហើយនឹង

ក៖  បាទមីង ចុះមីងមានបងប្អូន
រឺមួយក៏កូនចៅណាមួយដែរទៅរស់នៅប្រទេសក្រៅដែរទេមីង?

ខ៖  អត់មានទេ

ក៖  ចុះបងប្អូនកូនក្មួយក៏អត់មានដែរណាមីង?

ខ៖  អត់មានទេ មានតែពូឥឡូវនឹងគាត់មករស់នៅភ្នំពេញវិញហើយនឹង
គាត់មកទិញផ្ទះមួយមកនៅភ្នំពេញវិញនឹង

ក៖  ចុះកាលពីមុនគាត់នៅណាដែរមីង?

ខ៖  គាត់នៅកាលីហ្វ័រញ៉ា

ក៖  នៅកាលីហ្វ័រញ៉ា ដែរនៅឯាមេរិចណាមីង?

ខ៖ ចា៎!នៅណុង

ក៖ ចុះស្វាមីរបស់មីងមានឈ្មោះអីគេដែរមីង?

ខ៖ គាត់មានឈ្មោះហុច

ក៖ ឈ្មោះ ហុច ចុះមីងមានចងចាំថ្ងៃដែរមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយពូដែរទេមីង?

ខ៖ អត់ចងចាំទេ

ក៖ ប៉ុន្តែកូនបងរបស់មីងគាត់អាយុប៉ុន្មានដែរហើយមីង?

ខ៖ កូនបងរបស់ខ្ញុំនឹងអាយុ26ឆ្នាំ

ក៖ ចឹងមានន័យថាមីងការនឹងអស់រយះពេលប្រហែលជា27ឆ្នាំហើយមែនទេមីង?

ខ៖ ចា៎!នឹងហើយប្រហែលជាប៉ុណ្ណឹង

ក៖ ដូចជានៅពេលដែរមីងរៀបអាពាហ៍ពិពាហ៍ជាមួយពូនឹង ដូចជាឪពុកម្ដាយរបស់មីងជាអ្នករៀបអោយ រឺមួយក៏មីងជាអ្នករៀបដោយខ្លួនឯងដែរមីង?

ខ៖ ម៉ែឪរបស់ខ្ញុំនឹងយាយតា

ក៖ ប៉ុន្តែដូចជាមានជាថ្លៃជាជំនូនអត់មីង?

ខ៖ គ្មានទេ កាលណុងមានបន្តិចបន្តួចកាលពីជំនាន់ណុងគ្មានអីទេ ធ្វើតែបន្តិចបន្តួចទៅរួចហើយនឹងចឹងហាស

ក៖ ចុះមីងអាចប្រាប់ខ្ញុំបានទេ ថាពូចូលស្ដីដណ្ដឹងមីងបានទេ ថាគាត់ចូលស្ដីនៅពេលណាហើយស្រលាញ់គ្នាប៉ុន្មានឆ្នាំបានពូចូលស្ដីចឹងហាសមីង?

ខ៖ មិនដឹងទេរឿងនឹង មិនដឹងថានៅថ្ងៃណា ខែណាមិនដឹងទេ

ក៖ អូ៎!មីងមិនច្បាស់ទេណាមីង?

ខ៖ ចា៎!ខ្ញុំមិនច្បាស់ទេ

ក៖ ចុះមីងធ្លលាប់បានរៀនភាសាខ្មែរទេ ពីមុនមកហាស?

ខ៖ គ្មានទេ គ្មានទៅបានរៀនទេ បានតែបន្តិចបន្តួចនឹង គ្មានសូវបានចេះអក្សរនឹងគេទេ

ក៖ ប៉ុន្តែមីងធ្លាប់បានចូលរៀនមែនទេមីង?

ខ៖ ចា៎!ធ្លាប់ចូលសាលាដែរតា

កៈ ប៉ុន្តែរៀននៅណាដែរមីង?

ខៈ រៀននៅស្វងនឹងតែម្តងនឹង

កៈ អូ៎! ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរអត់?

ខៈ អត់ចេះទេ

កៈ ភាសាថៃ វៀតណាមអីក៏មីងមិនចេះដែរ?

ខៈ អត់ទេមួយម៉ាត់ក៏មិនចេះដែរ ខ្ញុំខ្មែរសុទ្ធ

កៈ ចុះមីងធ្លាប់មានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាអត់មីង?

ខៈ មានដែរប៉ុន្តែគេបែកទៅដល់ណា បាត់ហើយមិនដឹងថាទៅដល់ណាផង
មានតែម្នាក់នឹងរៀនជាមួយគ្នាបានតែមួយអាទិត្យនឹង
រៀនជាមួយគ្នាហើយគេបែកទៅរហូតនឹង ម៉ែឪគេលែងលះគ្នាទៅគេទៅបាត់ទៅណាស់

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរទៅមីង?

ខៈ មានឈ្មោះហួន

កៈ ឈ្មោះហួន ចុះមីងមានចងចាំថា កាលពីមីងនៅក្មេងនឹង
មីងធ្លាប់បានលេងអីជាមួយគាត់ខ្លះដែរទេមីង?

ខៈ គ្មានទេបានតែទៅរៀននឹង លេងតែលោតអន្ទាក់លោតអីជាមួយគ្នាតែប៉ុណ្ណឹងឯង

កៈ មីងធ្លាប់ទៅស្រែអីជាមួយគ្នាដែរតាហីមីង?

ខៈ ធ្លាប់ទៅធ្វើស្រែចំការអីជាមួយគ្នាដែរនឹង

កៈ អូ៎!ធ្លាប់ទៅធ្វើស្រែចំការណមីង?

ខៈ ចា៎! មានតែប៉ុណ្ណឹង

កៈ ចុះមីងធ្លាប់បានធ្វើអីគេខ្លះតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខៈ គ្មានទេ មានតែធ្វើស្រែ នឹងធ្វើចំការនឹង

កៈ មីងធ្លាប់ទៅធ្វើស្រែដែរ ចុះចំការមីងមានធ្លាប់ធ្វើទេ?

ខៈ ខ្ញុំធ្លាប់ធ្វើដែរតា

កៈ ចុះមីងមានធ្លាប់ធ្វើអីគេខ្លះនៅស្រែចំការដែរមីង?

ខ៖ នៅស្រែខ្ញុំធ្វើតែស្រូវនឹង ហើយនៅចំការខ្ញុំដាំពោត នឹងដាំដំឡូង

ក៖ អូ៎!មីងមានចំការពោត នឹងចំការដំឡូងដែរហោសមីង?

ខ៖ ចា៎!មានចំការពោត នឹងចំការដំឡូងចឹងទៅចេះតែដាំទៅ មានសណ្ដែកបាយ នឹងសណ្ដែកសៀងអីចឹងទៅចេះតែដាំទៅ កាលពីនៅតូចៗហោស ប៉ុន្តែឥឡូវនឹងខ្ញុំមកនៅនេះយូរដែរហើយនឹង

ក៖ ប៉ុន្តែខមការនឹងនៅទេ?

ខ៖ នឹងកេរ្តិ៍ឪពុកម្ដាយរបស់ខ្ញុំទេ

ក៖ អូ៎!កេរ្តិ៍ឪពុកម្ដាយ?

ខ៖ នឹងហើយកេរ្តិ៍យាយតា ចែកអោយឪពុកម្ដាយរបស់ខ្ញុំ ម្នាក់បានបន្តិចៗនឹង

ក៖ ប៉ុន្តែឪពុកម្ដាយរបស់មីងគាត់ចែកតដែរ?

ខ៖ គាត់ចែកត ប៉ុន្តែមិនបានខ្ញុំទេ បានទៅលើប្អូនរបស់ខ្ញុំនឹង

ក៖ ម៉េចបានមីងមិនបានចឹង?

ខ៖ មកពីខ្ញុំមិនបាននៅបំរើគាត់ចឹងហាស ខ្ញុំបានប្ដីមកឆ្ងាយ ហើយអ្នកដែរបំរើគាត់ថែរក្សាអោយគេយកទៅខ្ញុំគ្មានអី

ក៖ ប៉ុន្តែមីងមិនដែរចង់បានទេណាមីង?

ខ៖ អត់មានទេ មានប៉ុន្មានប៉ុណ្ណឹង បើអត់ៗក៏អត់ទៅ

ក៖ ចុះមីងមានធ្លាប់ធ្វើអាជីវកម្មនៅក្នុងក្រុមគ្រួសារដែរទេមីង?

ខ៖ ខ្ញុំមានតែលក់ដូរបន្តិចបន្តួចទៅតាមវត្ត តាមអីចឹង

ក៖ ភាគច្រើនមីងលក់អីគេដែរមីង?

ខ៖ ខ្ញុំមានលក់តែស្រាបន្តិចបន្តួចអីតែប៉ុណ្ណឹង កាលពីដើមមក

ក៖ អូ៎!មីងលក្ខណះថាលក់ឥវ៉ាន់ចាប់ហួយអីចឹងណាមីង?

ខ៖ ខ្ញុំមានលក់តែប៉ុណ្ណឹង

ក៖ ចុះកាលពីមុនមីងធ្លាប់ដែរចិញ្ចឹមសត្វទេ ដូចជាលក្ខណះថាចិញ្ចឹមគោ មាន់ ទា ជ្រូក ក្របីអីចឹងហាស?

ខ៖  មានខ្ញុំមើលក្របី គោ ជ្រូកអីខ្ញុំចេះតែមើលហើយនឹង
ផ្ទះខ្ញុំត្រូវការដែរចុះនៅស្រុកស្រែនោះ

ក៖  បាទមីង ចុះមីងចិញ្ចឹមលក្ខណះជាច្រើន រឺមួយក៏ចិញ្ចឹមតិចដែរមីង?

ខ៖  មានចិញ្ចឹមពីរ ទៅបីនឹង

ក៖  អូ!មីងចិញ្ចឹមលក្ខណះតែពីរ ទៅបីទេហោសមីង?

ខ៖  យើងគ្មានចិញ្ចឹមច្រើនអីទេគ្រាន់តែសំរាប់ភ្ជួរស្រែអីចឹងទៅណាស់
ចុះកាលពីជំនាន់ណុងមានម៉ាស៊ីនមកពីណា មិនមែនដូចឥឡូវនឹងទេ

ក៖  ចុះមីងគិតថាជីវិតរបស់មីងតាំងពីក្មេងរហូតមកដល់ពេលនេះនឹង
តើមានការផ្លាស់ប្តូរអីគេខ្លះដែរទៅមីង?

ខ៖  មានការផ្លាស់ប្តូរច្រើនណាស់

ក៖  ចុះមីងអាចរៀបរាប់ខ្លះៗបានទេមីង?

ខ៖  មានការផ្លាស់ប្តូរដូចជាអត់ហាត់ដូចពីដើមនឹង ការពីដើមវាហាត់ណាស់
ឥឡូវនឹងវាអាចរកស៊ីតាមប្រាជ្ញាអីចឹងទៅយើងអាចរស់បានចឹងហាស

ក៖  កាលពីដើមមីងធ្វើអីគេទៅ?

ខ៖  លក់បាយ កាប់អូស កាប់អីសព្វបែបយ៉ាងចឹងទៅ

ក៖  ចុះមីងចូលចិត្តពិសារម្ហូបអីគេដែរទៅមីង?

ខ៖  ម្ហូបអ្នកស្រែមានតែស្លប្រហើរ នឹងស្លម្ជូរនឹងមានស្អី

ក៖  នឹងដែរមីងចូលចិត្ត ចុះសម្លកកូរ សម្លខ ការីអីមីងចូលចិត្តទេ?

ខ៖  ចាំ!នឹងហើយចេះតែហូបទៅធម្មតានឹងគ្មានសូវចូលចិត្តអីទេ

ក៖  អូ!ចឹងហោសមីង?

ខ៖  និយាយពីសំលកកូរ សំលប្រហើរអីនឹងវាធម្មតានឹង

ក៖  ចុះតាំងពីក្មេងហាស តើល្បែងប្រជាប្រិយ៍អីដែមីងចូលចិត្តលេងដែរ ដូចជាបោះអង្គុញ
ទាញព្រាត លាក់កន្សែង ចោលឈូងអីចឹង?

ខ៖  នឹងលេងតែចឹង កាលពីក្មេងនឹងលេងតែចឹង

កៈ ប៉ុន្តែមីងចូលចិត្តលេងអីជាងគេដែរមីង?

ខៈ ខ្ញុំចូលចិត្តលេងតែមឹកចិនម៉េចហោស អាលក្ខណៈថាគេលេងដេញចាប់គ្នានោះ

កៈ អ៊ូ!មឹកដេញចាប់នឹងហោសមីង?

ខៈ នឹងហើយអាមឹកដេញចាប់គ្នានឹង ខ្ញុំលេងតែអានឹង

កៈ ចុះមីងចេះច្រៀងទេមីង?

ខៈ មិនចេះទេច្រៀងនោះ

កៈ ប៉ុន្តែមីងចូលចិត្តស្តាប់បទចំរៀងទេ?

ខៈ មិនដែរនឹងបានមើលទូរទស្សន៍ទេ

កៈ ចុះលក្ខណៈថាស្អីកគេដែរមីងគិតថាចូលចិត្តមើល ដូចជាស្តាប់ពិតមាន រឺមួយក៏មើលល្ខោនអីចឹងទៅ?

ខៈ អត់ទេនឹងគ្មានទៅចូលចិត្តទេ ល្ខោនលេងៗទៅ ខ្ញុំអត់មើលផងនឹង

កៈ ចុះមីងគិតថាមាននរណាម្នាក់នៅក្នុងផ្ទះរបស់មីង នឹងគេចេះលេងឧបករណ៍ភ្លេងទេ?

ខៈ គ្មានទេ

កៈ ភ្លេងសៀម ភ្លេងពិនពាតអីក៏អត់ចេះដែរ?

ខៈ អត់មាននរណាគេចេះទេ

កៈ ចុះផ្ទះរបស់មីងមានលក្ខណៈបែបនាដែរទៅមីង?

ខៈ និយាយពីគ្រួសារនឹងចេះតែលំបាកពេកណាស់ហើយ ប៉ុន្តែចេះតែរស់នៅទៅ

កៈ តាំងពីក្មេងរហូតមកដល់ពេលនេះនឹងដូចជាយ៉ាងម៉េចដែរទៅ?
ខៈ ចេះតែទ្រាំរស់ទៅ

កៈ ប៉ុន្តែផ្ទះមានលក្ខណៈបែបណាដែរមីង លក្ខណៈផ្ទះឈើ ផ្ទះថ្មចឹងហាសមីង?

ខៈ វានឹងគ្រាន់តែថាស្រួលជាងផ្ទះឈើបន្តិចនឹង វាគ្រាន់តែថារៀងស្អាតដែរនឹង

កៈ ចុះមីងគិតថាផ្ទះរបស់មីងនឹងពេលដែរធ្វើនឹងនរណាគេជាអ្នកធ្វើដែរ មីងជួលគេ រឺមួយក៏មីងធ្វើដោយខ្លួនឯងដែរមីង?

ខៈ ខ្ញុំធ្វើខ្លួនខ្ញុំ ជួលគេធ្វើអី

កៈ ប៉ុន្តែផ្ទះរបស់មីងធ្វើនឹង គិតថាគេប្រើឧបករណ៍អីគេខ្លះសំរាប់ធ្វើវាដែរមីង?

ខៈ មានឈើ ដែក សីម៉ង់ ការ៉ូ អត់អីទេមានសព្វគ្រប់នឹង

កៈ ចុះមីងគិតថាមានជំនាញអីដែរមីងគិតថាមីងចេះធ្វើស្ទាត់ជំនាញដែរទេមីង?

ខៈ គ្មានអីទេរឿងមុខរបរនឹង

កៈ ចុះមីងគិតថាឪពុកម្តាយរបស់មីងគាត់មានធ្លាប់បង្រៀនអីទៅមីងដែរទេ ដូចជាវេញវល្លិ៍ ធ្វើស្កុរ ធ្វើផ្តៅអីទេមីង?

ខៈ គ្មានទេតែកន្ទេលនឹងមិនចេះធ្វើផងនឹង

កៈ ចឹងមានន័យថាមីងជំនាញជាងគេគឺលក់ដូរណាមីង?

ខៈ ចាំ! លក់ដូរនឹង មានបន្តិចបន្តួចនឹងចេះតែរស់ទៅ

កៈ ចុះមីងអាចប្រាប់បានទេថា
ពេលណាដែរមីងគិតថាលំបាកជាងគេនៅក្នុងជីវិតរបស់មីង
លក្ខណៈថាការពីជំនាន់ពលពត រឺមួយក៏កាលពីនៅក្មេងអីចឹងហាស?

ខៈ ចុះកាលពីជំនាន់ពលពតយើងពិបាកហោស យើងគ្មានអីហូបហោស
រកតែបាយហូបគ្មានផងពេលណុងហោស

កៈ ចុះពេលណុងមីងនៅណាដែរ?

ខៈ ខ្ញុំនៅស្រុកនឹង អត់មានជំលាសទេ

កៈ ចឹងមានន័យថាអត់មានជំលាសទៅណាសចឹង
ប៉ុន្តែពេលណុងគេអោយមីងធ្វើអីគេដែរទៅ?

ខៈ
គេអោយកាប់កន្រ្ទាំងខេត្តគេអោយកើបអាចម៍គោអីចឹងហើយដាក់រោងអោយយើងហូបបានបាយអីចឹងហាស?

កៈ អូ៎!ពេលណុងគេអោយមីងនៅជាមួយគ្រួសារហោស?

ខៈ ចាំ! នៅជាមួយគ្រួសារ ខ្ញុំនៅតូចនឹង

កៈ ប៉ុន្តែគេអត់អោយមីងទៅណា រឺមួយក៏បងប្អូនរបស់មីងទៅណាអីទេ?

ខៈ អត់មានទេ មានតែបងរបស់ខ្ញុំធ្វើកងចល័តមួយដែរនឹង

កៈ របៀតទាល់តែដាច់ពលពតតែម្ដងនឹង ចុះមីងគេអោយរបបអាហារយ៉ាងម៉េចដែរមីង?

ខៈ មួយថ្ងៃគេអោយពីរដង មានថ្ងៃត្រង់ នឹងពេលល្ងាច

កៈ ប៉ុន្តែពេលណុងមីងអាយុប៉ុន្មានដែរទៅមីង?

ខៈ ខ្ញុំអាយុ5-6ឆ្នាំអីនឹង

កៈ អាយុ5-6ឆ្នាំប្រហែលជាប៉ុននេះហើយណាមីង?

ខៈ ចា៎!ប្រហែលជាប៉ុណ្ណឹង

កៈ ប៉ុន្តែពេលណុងគេអោយទៅកើបអាចម៍គោដែរ?

ខៈ គេអោយកើបតា បើមិនទៅកើបអាចម៍គោគេម៉េចអោយបាយហូបទៅ

កៈ ប៉ុន្តែគេអោយធ្វើតែប៉ុណ្ណឹង?

ខៈ គេអោយកើបអាចម៍គោ គេអោយកាប់កន្រ្តាំងខេត្ត កើបអាចម៍គោ អាចម៍ក្របីដែរ

កៈ ប៉ុន្តែគេអោយទៅគ្នាច្រើនៗមែនទេមីង?

ខៈ ចា៎!មានតាមទ័ពគេដែរ មានកុមារមានមួយក្រុមមាន20-30នាក់ចឹងទៅ

កៈ គេហៅថាកងចល័តកុមារមែនទេមីង?

ខៈ ចា៎!គេហៅកុមារ ក្រុមកុមារចឹងគេអោយទៅមួយក្រុមៗចឹងទៅ
ហើយគេដាក់មួយក្រុមៗទៅ
នៅកន្លែងរៀនគេដាក់មួយក្រុមៗទៅដែរចឹងនៅស្រុកខ្ញុំគេអោយធ្វើចឹង

កៈ ចុះក្មេងៗគេអោយគេងជាមួយគ្រួសារ
រឺមួយក៏គេអោយគេងជាមួយក្រុមក្មេងៗគ្នាគេទៅមីង?

ខៈ ខ្ញុំគេអោយនៅជាមួយគ្រួសារទេ
ប៉ុន្តែអ្នកខ្លះដែរគេអោយនៅជាក្រុមៗគេងនៅរោងបាយអីចឹងទៅណាស់

កៈ អូ៎!លក្ខណៈថាគេជាជំរៀបជួរគ្នាចឹងទៅ?

ខៈ នឹងម៉ែឪរបស់ខ្ញុំគាត់ថាមិនចង់អោយខ្ញុំទៅណាទេ

កៈ ប៉ុន្តែពេលណុងក្រុមគ្រួសាររបស់មីងគេអោយធ្វើអីគេទៅ?

ខៈ ពុករបស់ខ្ញុំនេសាទត្រី ម៉ែរបស់ខ្ញុំគេអោយនេសាទដែរ

កៈ  អូ!គេអោយនេសាទដែរ ប៉ុន្តែនេសាទទៅគេដាក់ជារួមរឺយ៉ាងម៉េចដែរមីង?

ខៈ  គេអោយដាក់ជារួមគេយើងមិនអាចហូបបានទេ

កៈ  ចឹងគ្រួសាររបស់មីងមិនសូវមានការលំបាកអីទេណាមីង?

ខៈ  អត់សូវមានទេ

កៈ  នឹងកាលពីជំនាន់ពលពត?

ខៈ  នឹងហើយពីព្រោះគ្រួសាររបស់ខ្ញុំរៀងស្រួល ពីព្រោះឪពុករបស់ខ្ញុំគាត់ចេះរកត្រីហាស រកបានគេអោយហូបជុំគ្នានៅក្នុងរោងបាយចឹង

កៈ  ហូបជុំគ្នាទាំងអស់នឹង?

ខៈ  នឹងហើយគេមិនអោយហូបនៅផ្ទះទេ

កៈ  មានហូបគ្នាច្រើនហើយចឹង?

ខៈ  មានរោងគេធ្វើមួយចឹងទៅប៉ុន្តែវាវែងហាស នៅក្នុងភូមិនឹង

កៈ  អូ!គេធ្វើចឹងហោស?

ខៈ  នឹងហើយគេមិនអោយហូបនៅផ្ទះទេគេដាំបាយឆ្អិនគេហៅយើងហើយនឹង ដល់ពេលដែរដល់ម៉ោងគេដឹងហើយ មិនបាច់ចាំគេហៅទេ ទៅអង្គុយចាំគេទៅណាស់

កៈ  អូ!មិនបាច់គេហៅទេណាមីង?

ខៈ  នឹងហើយតែដល់ម៉ោងចេញពីធ្វើការងារនឹងទៅអង្គុយចាំគេនឹង

កៈ  អូ!ប៉ុន្តែកុមារចឹងគេអោយធ្វើប៉ុន្មានម៉ោងទៅមីង?

ខៈ  ធ្វើមួយព្រឹកដល់ថ្ងៃត្រង់ចឹងទៅធ្វើដល់ម៉ោង9-10អីចឹងដែរនឹង

កៈ  អូ! ធ្វើដូចតែគ្នាដែរនឹងហោសមីង?

ខៈ  ចា៎!ធ្វើដូចតែគ្នាដែរនឹង

កៈ  ប៉ុន្តែគ្រាន់តែការងារកុមារមានតិចជាងហីមីង?

ខៈ  ចា៎! មានធ្វើការតិចជាមនុស្សធំ មនុស្សធំធ្វើច្រើន មានជីកស្រះជីកប្រឡាយអីចឹងទៅ

កៈ  ប៉ុន្តែបងរបស់មីងគេអោយទៅធ្វើអីគេដែរទៅមីង?

ខៈ  បងប្រុសរបស់ខ្ញុំនឹងហោស ?

កៈ បាទបងរបស់មីងគេអោយធ្វើអីគេ?

ខៈ បងប្រុសរបស់ខ្ញុំគេអោយជីកដី នឹងជីកស្រះ លក្ខណៈថាជំនាន់អាពតគេហៅថាជាកំលាំងស្រួចម៉េចគេទេនេះ

កៈ កំលាំងកងស្រួចហីមីង?

ខៈ នឹងហើយកំលាំងគេខ្លាំងហាស

កៈ ចឹងដូចជាមីងឆ្លងកាត់ឧបសគ្គមួយនឹងដោយរបៀបណាដែរមីង?

ខៈ មិនដឹងជាយ៉ាងណាអីទេ វាយ៉ាប់តែម្តងនឹង ប៉ុន្តែខ្ញុំមិនបានបែកគ្រួសារអីទេ នៅជុំគ្នាទាំងអស់នឹងគ្នាបែកទៅណាទេ គ្រាន់តែវាហាត់នឿយនឹងការរកស៊ីដែរ

កៈ ប៉ុន្តែគេមិនបានអោយយើងជំលាសទៅណាអីអត់មានទេណាមីង?

ខៈ អត់មានទៅណាទេ

កៈ នៅតែមួយកន្លែងនឹង ចុះពេលដែរដាច់ពលពតនឹង គ្រួសាររបស់មីងគេអោយទៅធ្វើអីគេដែរទៅមីង?

ខៈ ធ្វើស្រែ ធ្វើចំការធម្មតានឹង

កៈ ប៉ុន្តែគេមិនអោយទៅចាប់ដីអីនៅណាទេណាមីង?

ខៈ គ្មានទេ

កៈ ពេលណុងយើងយកផ្ទះយើងដដែរ?

ខៈ ចាំ!យើងយកផ្ទះដដែរ នឹងយកដីដដែរនឹង គេគ្មានជំលាសអោយទៅណាទេ

កៈ ចុះពេលដែរមីងមានការលំបាក តើមីងគិតថាមានការលំបាកអីគេខ្លះដែរទៅមីង?

ខៈ អត់មានការលំបាកអីទេ

កៈ នៅពេលដែរមីងចាប់ផ្តើមមានគ្រួសារហាសគិតថាមានការលំបាកអីគេដែរទៅមីង?

ខៈ គ្មានការលំបាកអីទេ មានប៉ុណ្ណារស់នៅប៉ុណ្ណឹង

កៈ អូ៎!មីងមករស់នៅនឹងរហូតតែម្តងនឹងដែរមីងមានក្រុមគ្រួសារនឹង?

ខៈ ចាំ!មកនៅភ្នំពេញតែម្តងនឹង

ក៖ ចុះមីងគិតថានៅពេលដែរមីងមានកូនហាស តើមីងគិតថាមានការលំបាកអីអត់ចឹងមីង?

ខ៖ អត់មានទេ

ក៖ ចឹងគ្មានទេណាមីង?

ខ៖ នឹងហើយគ្មានទេនឹង

ក៖ ចុះមីងគិតថាពេលណាដែរមីងគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់មីងដែរចឹងទៅមីង?

ខ៖ គ្មានអីជាងជួបជុំបងប្អូនទេ ពេលដែរតៅស្រុកម្ដងៗនឹងវាសប្បាយណាស់

ក៖ អូ៎!នៅពេលដែរមីងបានជួបជុំបងប្អូន រឺមួយក៏មីងជួបជុំកូនចៅ រឺមួយក៏ការកូនចៅអីចឹងហោសមីង?

ខ៖ ចា៎!នឹងហើយវាចឹង

ក៖ ចឹងពេលដែរជួបគ្នាសប្បាយណាមីង?

ខ៖ ចា៎!ជួបជុំកូនចៅវាសប្បាយណាស់

ក៖ ចុះតាំងពីក្មេងមីងធ្លាប់មានក្ដីស្រម៉ៃថា ពេលដែរចំឡើងមីងចង់ធ្វើជាស្អីគេដែរទេមីង?

ខ៖ ខ្ញុំស្រម៉ៃថា ពេលដែរធំឡើងអត់ចង់ធ្វើស្រែ ចង់តែរកស៊ីនឹង នឹងលក់ដូរអីតិចតួចអាចរស់បានទៅបានហើយ

ក៖ អូ៎!មីងស្រម៉ៃចឹងហោសមីង?

ខ៖ ចា៎! ដល់ពេលចឹងបានតាមក្ដីស្រម៉ៃដែរ វាមករស់នៅមួយមេឃ មួយដីនេះ

ក៖ បាទមីងឆ្ងាយដែរ?

ខ៖ នឹងហើយស្រុកនៅកំពង់ចាម ឥឡូវនឹងវាមកដល់ភ្នំពេញណា

ក៖ បាទមីងចឹងមីងសម្រេចគោលបំណងនឹងការងាររកស៊ីបានហើយណាមីង?

ខ៖ ចា៎! មិនបានអីច្រើនទេគ្រាន់តែថាយើងអាចរស់នៅបានចឹងទៅ

ក៖ ចុះកាលពីមីងនៅរៀន តើមីងគិតថា មីងមានចង់ធ្វើជាគ្រូពេទ្យ រឺចង់ធ្វើជាគ្រូបង្រៀនអីទេមីង?

ខ៖ គ្មានទេ អត់មានទេ

ក៖ ចង់ធ្វើជាប៉ូលីសអីក៏អត់ដែរ?

ខ៖ អត់មានដែរទេ

ក៖ ចុះនៅពេលដែរចុងក្រោយ បើចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយ
តើមីងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរទៅមីង?

ខ៖ ខ្ញុំចង់អោយកូនរកស៊ីផ្លូវល្អក្នុងឆាកជីវិតអីចឹងហាស

ក៖ ចុះមីងមានអីចង់ផ្ដែផ្ដាំអីទៀតទេមីង?

ខ៖ គ្មានអីទៀតទេអូន

ក៖ លក្ខណៈថាចង់អោយពួកគាត់ជៀសផុតហាស
តើមីងចង់អយពួកគាត់ជៀសីអីគេដែរមីង?

ខ៖ អោយជៀសពីគ្រឿងញៀនអីនឹងហាស

ក៖ បាទត្រូវហើយមីង?

ខ៖ បើមានកូនចៅ នឹងកូនអោយជៀសផុតពីគ្រឿងចឹង
គ្រាន់តែមិនចង់អោយឃើញថាឆ្កួតអីនឹងហាស ប៉ុណ្ណឹង

ក៖ ចង់អោយពួកគាត់មានការងារល្អធ្វើអីចឹងហាសមីង?

ខ៖ ចង់អោយពួកគាត់មានការងារល្អដូចអូនឯងអីចឹងហាស

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់មីង
ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា

ខ៖ ចា៎!អរគុណច្រើនអូន?

ក៖ ដើម្បីអោយគាត់អាចមានការងារល្អធ្វើនៅក្នុងក្រុមគ្រសាររបស់គាត់
នឹងរឿងអីផ្សេងទេ

ខ៖ ចឹងជាចុងទឹកកកនឹង

ក៖ កូនចៅអី ពីប្រព្រឹត្តិចឹង ចៅគេបានប្រពឹត្តិចឹងហាសមីង

ខ៖ ចឹងហើយ

កៈ ចឹងមួយទៀតខ្ញុំអោយមីងមានសុខភាពល្អអីចឹងហាសមីង?

ខៈ ចាំ!អរគុណច្រើន

កៈ នឹងមីងអាចជួយដើម្បីអោយមីងអាចរកស៊ីមានបាននៅក្នុងគ្រួសារចឹងហាស នឹងពួកគាត់អាចសំរេចសម្រេចនៅគោបំណង់របស់មីចឹងហាសមីង?

ខៈ ចាៈ អរគុណច្រើនក្មួយ

កៈ បាទចឹងអរគុណច្រើនដែរចឹងហាសមីង បាទអរគុណច្រើនមីង៕៕៕